# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 28-Jul-2011, 12:17
CMS/CFO: Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ:/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសំណើសុំឲ្យមានសវនាការផ្ទាល់មាត់**

---

**ដាក់ដោយ:**

**សហមេធាវី:**

អាង ឧត្ដម

Michael G. KARNAVAS

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន** ប្រធាន

ចៅក្រម **ធូ មណី**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **យូរ ឧត្តារា**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈមេធាវីរបស់គាត់ (“ក្រុមមេធាវីការពារក្តី”) តទៅនេះសូមឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា (“ក.ស.ព”) ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (“សំណើ”)[១]។ សំណើនេះ គួរបដិសេធចោល ដោយសារសំណើនេះជាអញ្ញត្រកម្មមួយដែលលើកឡើងមិនទាន់ពេលវេលា ដើម្បីជំទាស់ទៅនឹងការសម្រេចយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ ដែលសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឲ្យមានទំនាក់ទំនង នៃជម្លោះប្រដាប់អាវុធរវាងសកម្មភាពជាមូលដ្ឋាននានា និងជម្លោះប្រដាប់អាវុធ។ មួយវិញទៀត សំណើនេះគួរបដិសេធចោល ដោយសារកង្វះអង្គសេចក្តី។ ចំពោះបញ្ហាថាតើធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមបញ្ចូលទំនាក់ទំនងរវាងសកម្មភាពជាក់លាក់នានា និងជម្លោះប្រដាប់អាវុធនោះឬយ៉ាងណានោះ ត្រូវបានប្តឹងជំទាស់យ៉ាងទូលំទូលាយ។ សំណើនោះ ខកខានមិនបានបង្ហាញអំពីកំហុសឆ្គងណាមួយដែលគេអាចវិនិច្ឆ័យបាន នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលតម្រូវឲ្យមានការកែប្រែពីសំណាក់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ ក្រុមមេធាវីការពារក្តីសូមយោងសំអាងផ្លូវច្បាប់ទាំងឡាយក្នុងសារណាមុនៗរបស់ខ្លួន ស្តីអំពីបញ្ហានានាពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាន និងអង្គសេចក្តីរបស់សំណើ[២]។ ក្រុមមេធាវីការពារក្តីសូមស្នើឲ្យមានការរៀបចំសវនាការផ្ទាល់មាត់ជាសាធារណៈផងដែរ។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ក្រុមមេធាវីការពារក្តីបានដាក់ញត្តិផ្សេងទៀតរបស់ លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អ.វ.ត.ក (“ញត្តិ”) នៅចំពោះមុខ ក.ស.ច.ស[៣] រួមជាមួយឧបសម្ព័ន្ធយោង[៤]។ ញត្តិទាមទារឲ្យមាន

---

[១] សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E95។

[២] *សូមមើល* សេចក្តីផ្តើម។

[៣] ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អវតក, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ D378/2។

[៤] ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អវតក, ឧបសម្ព័ន្ធ: វិវឌ្ឍភាពទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការវិវឌ្ឍន៍របស់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ D378/2.2 (“ឧបសម្ព័ន្ធរបស់ញត្តិ”)។

ការកម្រិតនិយមន័យ របស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក ឲ្យនៅត្រឹមនិយមន័យរបស់ឧក្រិដ្ឋកម្មនានានៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ញត្តិបានពន្យល់បកស្រាយអំពីមូលហេតុអ្វីបានជាគោលការណ៍នីត្យានុកូលភាពតម្រូវថា នៅ អ.វ.ត.ក សកម្មភាពជាក់លាក់នានានៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាមទារឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធអន្តរជាតិ (ប្រសិនបើ អ.វ.ត.ក មានយុត្តាធិការកាត់សេចក្ដីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ)[៥]។ ឧបសម្ព័ន្ធនៃញត្តិនោះ បានបន្តពន្យល់បកស្រាយបន្ថែមទៀតថា ដើមកំណើតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរីកចម្រើនជាលំដាប់នៃធាតុផ្សំទូទៅរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងនោះ (រួមមាន លក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធអន្តរជាតិ) ទាំងមុន និងនៅក្រោយ រយៈពេលយុត្តាធិការបណ្ដោះអាសន្នរបស់ អ.វ.ត.ក[៦]។ ក.ស.ព មិនបានឆ្លើយតបទៅនឹងញត្តិ ហើយ ក.ស.ច.ស ក៏មិនបានសម្រេចលើញត្តិនេះដែរ។

២. នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១០ ក្រុមមេធាវីការពារក្ដី បានដាក់ចម្លើយតបរបស់ លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងការអង្កេតបន្ថែមនានា[៧]។ ក្រុមមេធាវីការពារក្ដី សូមលើកឡើងជាថ្មីម្ដងទៀត អំពីគោលជំហររបស់ខ្លួន ដែលអះអាងថា "ចំណងទាក់ទងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ គឺជាលក្ខខណ្ឌតម្រូវមួយរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អ.វ.ត.ក ទោះបីលក្ខខណ្ឌតម្រូវនេះ មិនត្រូវបានគូសបញ្ជាក់ឲ្យបានច្បាស់ នៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ក៏ដោយ"[៨]។

---

[៥] ញត្តិ កថាខណ្ឌ ៨-៩។

[៦] ឧបសម្ព័ន្ធរបស់ញត្តិ កថាខណ្ឌ ៣-២១។

[៧] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងការអង្កេតបន្ថែមមួយចំនួន, ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D390/1/2/1.3។

[៨] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ៣២-៣៣។

៣. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ក.ស.ច.ស បានដាក់ដីកាដំណោះស្រាយបឋម នៅក្នុងសំណុំរឿង ០០២[៩]។ ក.ស.ច.ស មិនបានយោងដល់លក្ខខណ្ឌតម្រូវនៃទំនាក់ទំនងរវាងអំពើជាមូលដ្ឋានរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធឡើយ។

៤. នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១០ ក្រុមមេធាវីការពារក្តី បានដាក់បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[១០]។ ក្រុមមេធាវីការពារក្តី បានលើកឡើងថា "ក.ស.ច.ស មានកំហុសឆ្គងដោយពុំបានពន្យល់ថា ចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ គឺជាលក្ខខណ្ឌតម្រូវមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ អ.វ.ត.ក[១១]" ហើយ ក្រុមមេធាវីការពារក្តី បានបញ្ជាក់ឡើងវិញយ៉ាងច្បាស់ម្តងទៀតពីសំអាងហេតុនានា ចំពោះការប្រកាន់យកគោលជំហរនេះ[១២]។

៥. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ក.ស.ព បានដាក់ចម្លើយតបរួមរបស់ខ្លួន ទៅនឹងបណ្តឹងឧទ្ធរណ៍ របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយលើកទឡ្ហីករណ៍ថា "ការហាមប្រាមទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ... មិនបានតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ ចន្លោះឆ្នាំ១៩៧៥-១៩៧៩ ទេ" ("ចម្លើយតប ក.ស.ព")[១៣]។ ក្រុមមេធាវីការពារក្តី បានធ្វើការឆ្លើយតបរបស់ខ្លួនទៅវិញ នៅថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១០[១៤]។

---

[៩] ដីកាដំណោះស្រាយ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427។

[១០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ឯកសារលេខ D427/1/6។

[១១] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៨៨។

[១២] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៨៨-១៨៩។

[១៣] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារលេខ D427/3/6 ផ្នែក I.2 កថាខណ្ឌ ១៧៥-១៨៥។

[១៤] សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ D427/1/23 ("សារណាឆ្លើយតប")។

៦. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះ បានចេញសាលដីការបស់ខ្លួន សម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ហើយមេធាវីការពារក្តីបានផ្អែកលើផ្នែកខ្លះៗធ្វើជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន៖

> មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាពដែលសហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងដោយខកខានពុំបានធ្វើការពិចារណាថា ក្នុងអំឡុងពេលយុត្តាធិការ តាមពេលវេលារបស់ អ.វ.ត.ក ច្បាប់ទំនៀមទម្លាប់អន្តរជាតិ តម្រូវឱ្យមានចំណងពាក់ព័ន្ធរវាងអំពើ ជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ។ "អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ" ត្រូវបានបូកបន្ថែមជាលក្ខខណ្ឌតម្រូវ "ធាតុផ្សំ" មួយនៅក្នុងផ្នែកទី IV (ក) ជំពូកបី នៃដីកាដំណោះស្រាយ[១៥]។

៧. នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានទទួលយកសំណុំរឿងក្តីមកចាត់ការ។ ការទទួលយកនេះ គឺជាការចាប់ផ្តើមនៃរយៈពេលសម្រាប់ការដាក់ជូននូវអញ្ញត្រកម្ម ដោយកាលបរិច្ឆេទកំណត់ខាងដើមសម្រាប់ការឈប់ទទួលយកអញ្ញត្រកម្មទាំងនោះ ត្រូវបានកំណត់ត្រឹមថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១[១៦]។ ក.ស.ព មិនបានដាក់អញ្ញត្រកម្ម ត្រឹមកាលបរិច្ឆេទកំណត់ខាងដើមនោះទេ។

៨. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ក.ស.ព បានដាក់បញ្ជីបញ្ហាច្បាប់ដែល ក.ស.ព មានបំណងចង់លើកនៅពេលសវនាការបឋម[១៧]។ នៅក្នុងបញ្ជីនេះ ក.ស.ព បានជូនសំណើដល់អង្គជំនុំជម្រះសាលាដំបូងថា ក.ស.ព នឹង៖ "*ស្នើសុំធ្វើការកំណត់បទចោទសាជាថ្មី នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមមាន* ៖ (ក) ជម្លោះប្រដាប់អាវុធមិនតម្រូវឱ្យមានការបង្ហាញសក្ខីកម្មពីអំពើឧក្រិដ្ឋ

---

[១៥] នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះ បានដាក់ចេញនូវសំអាងហេតុ សម្រាប់សាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ")។

[១៦] *សូមមើល* ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9។

[១៧] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបញ្ហាច្បាប់ដែលខ្លួនមានបំណងចង់លើកនៅពេលសវនាការបឋម, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/30។

ណាមួយ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ...”[១៨]

៩. នៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តី បានដាក់ការអង្កេត អំពីបញ្ហាច្បាប់របស់សហព្រះរាជអាជ្ញា (“ការអង្កេត”)[១៩]។ ក្រុមមេធាវីការពារក្តី បានលើកឡើងថា៖

> ក.ស.ព គួរតែបានលើកបញ្ហាទាំងនេះឲ្យបានត្រឹមត្រូវ មិនឲ្យហួសពីរយៈពេល៣០ថ្ងៃ ក្រោយពីដំណោះស្រាយចូលជាស្ថាពរ [អនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក]។ សហព្រះរាជអាជ្ញាមិនបានធ្វើយ៉ាងដូច្នេះទេ ហើយពេលនេះជាពេលវេលាដែលរារាំងសហព្រះរាជអាជ្ញា មិនឲ្យលើកបញ្ហា យុត្តាធិការទាំងនេះ។ បើទោះបីជាបញ្ហាទាំងនេះនៅតែអាចលើកឡើង ក៏វិធាន៨៩ មិនអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់បទចោទជាថ្មីដែរ។ បើសិនអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ក.ស.ព អាចលើកបញ្ហាទាំងនេះនៅសវនាការបឋម នោះមេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យ ក.ស.ព ផ្តល់សារណាជាលាយលក្ខណ៍អក្សរលម្អិតនៅមុនសវនាការបឋម ដោយបញ្ជាក់ពីអំណះអំណាងរបស់ខ្លួនថា ហេតុអ្វីបានកំណត់បទចោទជាថ្មី ត្រូវបានអនុញ្ញាត និងអនុញ្ញាតឲ្យមេធាវីការពារក្តីដាក់សារណាឆ្លើយតបជាលាយលក្ខណ៍អក្សរ[២០]។

១០. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ក.ស.ព បានដាក់ “ចម្លើយតប” មួយ[២១] ទៅនឹងការ

---

[១៨] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១(៩)។

[១៩] ការអង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបញ្ហាច្បាប់ដែលសហព្រះរាជអាជ្ញាមានបំណងលើកនៅសវនាការបឋម, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E9/30/1។

[២០] *ដូចជើងទំព័រខាងលើ* សេចក្តីផ្តើម (សម្រង់ផ្ទៃក្នុងត្រូវបានលុបចោល)។

[២១] អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងដល់ក្រុមមេធាវីការពារក្តីថា អង្គជំនុំជម្រះសាលាដំបូង ចាត់ទុកសារណាបែបនេះជាសារណាឆ្លើយតប មិនមែនជាចម្លើយតប ដូច្នេះ ឯកសារមួយនេះមិនគួរត្រូវបានទទួលយក និងដាក់នៅងសំណុំរឿងក្តីនោះទេ ដោយហេតុថា មិនមានការអនុញ្ញាតជាផ្លូវការពីសំណាក់អង្គជំនុំជម្រះជាមុន។ *សូមមើល* អ៊ីម៉ែល របស់អ្នកនាង Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនទៅក្រុមមេធាវីការពារក្តី អៀង សារី និងភាគីឯទៀត កាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ ដោយនៅក្នុងអ៊ីម៉ែលនោះ មានការបញ្ជាក់ថា ចម្លើយតបទៅនឹងការអង្កេតលើសារណារបស់ភាគីមួយផ្សេងទៀត នឹងត្រូវចាត់ទុកថាជាសារណាឆ្លើយតប មិនមែនជាចម្លើយតប នោះទេ។

អង្កេតរបស់ក្រុមមេធាវីការពារក្ដី ធ្វើឡើងនៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១[២២]។ ចម្លើយតប នោះ មានខ្លឹមសារថា៖

> សហព្រះរាជអាជ្ញាជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងអស់ថា ខ្លួន [sic] នឹងដាក់ជូននូវសេចក្ដីសន្និដ្ឋាន ដែលស្នើសុំឱ្យធ្វើការកំណត់បទចោទដែលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីឡើងវិញ នៅក្នុងសាលក្រម ... សហព្រះរាជអាជ្ញាមានបំណងនឹងដាក់ជូននូវសេចក្ដីសន្និដ្ឋានទាំងនេះ នៅមុនពេលសវនាការបឋម ឬយ៉ាងយូរបំផុតក៏នៅមុនពេលសវនាការលើអង្គសេចក្ដីដែរ។ ធ្វើដូចនេះ គឺជាការផ្ដល់ឱកាសដល់មេធាវីការពារក្ដីគ្រប់គ្នាទាំងអស់ ដើម្បីធ្វើការឆ្លើយតប ដូចជា អំពីភាពដែលអាចទទួលយកបាន និងអំពីអង្គសេចក្ដីដែលមាននៅក្នុងសំណើនេះ ដូចដែលមេធាវីបានស្នើសុំនៅក្នុងញត្តិស្នើសុំរបស់ពួកគេ[២៣]។

១១. នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្ដី បានជូនដំណឹងជាមុន ដល់អង្គជំនុំជម្រះសាលាដំបូង (តាមរយៈលិខិតមួយច្បាប់ ដែលត្រូវបានផ្ញើជូនដល់គ្រប់ភាគីទាំងអស់) អំពីការព្រួយបារម្ភជាក់លាក់មួយចំនួន រួមមាន ស្ថានភាពនៃចេតនារបស់ ក.ស.ព ដែលបានស្នើសុំ ដើម្បីដាក់ជូនជាសំអាង ស្ដីអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ("លិខិត")[២៤]។ នៅក្នុងលិខិតនេះ ក្រុមមេធាវីការពារក្ដី បានអះអាងឡើងវិញពីគោលជំហររបស់ខ្លួន ដែលលើកឡើងថា ក.ស.ព មិនអាចនឹងដាក់សំណើនានា ដើម្បីកំណត់បទចោទឡើងវិញ ព្រោះបញ្ហានេះវាហួសពេលវេលាកំណត់។

---

[២២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "សេចក្ដីសង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបញ្ហាច្បាប់ដែលខ្លួនមានបំណងលើកឡើងនៅពេលសវនាការបឋម", ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E9/30/2។

[២៣] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣-៤។ ក.ស.ព នៅបានអះអាងទៀតថា "*សំណើសុំកំណត់បទចោទថ្មីឡើងវិញ*" របស់ខ្លួនមិនអាចយកមកពិចារណាជាអញ្ញត្រកម្មនោះទេ។ *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៥-៦។

[២៤] លិខិតរបស់ក្រុមមេធាវីការពារក្ដី អៀង សារី ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង: សំណើសុំព័ត៌មាន ដើម្បីដាក់សារណាបន្ថែមពាក់ព័ន្ធនឹងអញ្ញត្រកម្ម របៀបវារៈ និងព័ត៌មានទាក់ទងនឹងសវនាការបឋម និងស្ថានភាពនៃសេចក្ដីសន្និដ្ឋានដែលបានលើកឡើងដោយ ក.ស.ព ពាក់ព័ន្ធនឹង JCE III និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១។

ក្រុមមេធាវីការពារក្តី សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ចេញដីកាបង្គាប់តាមការគួរ[២៥]។

១២. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ក.ស.ព បានដាក់សំណើ ដែលត្រូវបានជូនជាដំណឹង នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១។ នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង បានផ្ញើអ៊ីមែលមួយជូនទៅគ្រប់ភាគីទាំងអស់ ដែលមានអត្ថន័យថា ក្រុមមេធាវីការពារក្តី មានរយៈពេលរហូតដល់ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ដើម្បីឆ្លើយតបទៅនឹងសំណើ ចំណែក ក.ស.ព និងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលចំនួន ១០ថ្ងៃ ដើម្បីឆ្លើយតបវិញ[២៦]។ នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានសេចក្តីសម្រេចជាផ្លូវការ ដោយបានកែប្រែខ្លឹមសារក្នុងអ៊ីមែលថា ក្រុមមេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលរហូតដល់ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១១ ដើម្បីឆ្លើយតប ហើយ ក.ស.ព មានរយៈពេលសម្រាប់ឆ្លើយតប ត្រឹមថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១១[២៧]។

១៣. នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តីបានដាក់សំណើរបស់ លោក អៀង សារី ស្នើឲ្យមានសេចក្តីសម្រេចជាបន្ទាន់ ថាតើសហព្រះរាជអាជ្ញាអាចស្នើសុំឲ្យផ្លាស់ប្តូរការកំណត់បទចោទ នៅដំណាក់កាលនេះនៃនីតិវិធីដែរឬអត់ និងសំណើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនោះ បើសិនជាចម្លើយតបជាការចាំបាច់ ("សំណើសុំឲ្យមានសេចក្តី

---

[២៥] *ដូចដើងទំព័រខាងលើ* ទំព័រ ៣។ ក្រុមមេធាវីការពារក្តី បានដាក់សំណើបន្ថែមថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឲ្យ ក.ស.ព ដាក់សំអាងហេតុទាំងនោះ ក្រុមមេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់កាលបរិច្ឆេទផុតកំណត់ ព្រមទាំងទុកពេលវេលាសមស្របសម្រាប់ការឆ្លើយតប ដោយសារពេលវេលានេះ ជាពេលវេលាដ៏មមាញឹក នៅមុនពេលមានសវនាការបឋម និងនៅមុនពេលមានសវនាការអង្គសេចក្តី។

[២៦] អ៊ីមែលរបស់អ្នកនាង Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនទៅភាគី ស្តីអំពីសំណើឲ្យមានការកែតម្រូវកាលបរិច្ឆេទផុតកំណត់របស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងសំអាងហេតុចោទប្រកាន់ចំនួនបីនាពេលថ្មីៗនេះ ជូនដំណឹងជាមុនអំពីកាលបរិច្ឆេទផុតកំណត់សម្រាប់ការដាក់ឯកសារ/បញ្ជីវត្ថុតាងបន្ថែម (សម្រាប់ដំណាក់កាលដំបូងនៃសវនាការ), ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១។

[២៧] សេចក្តីសម្រេចលើសំណើសុំពន្យារពេល, ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E107។

សម្រេចជាបន្ទាន់")[២៨]។ នៅក្នុងសំណើសុំឲ្យមានសេចក្តីសម្រេចជាបន្ទាន់ ក្រុមមេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា៖ **ក.** ក.ស.ព បានលើកសំណើពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះដែលហួសរយៈពេលផុតកំណត់សម្រាប់ឲ្យលើកឡើងនូវបញ្ហាយុត្តាធិការនេះ[២៩] **ខ.**វិធាន៨៩ មិនអនុញ្ញាតឲ្យ ក.ស.ព ទាញអំណះអំណាងនានានៅសវនាការបឋម ដែល ក.ស.ព ខកខានមិនបានលើកឡើងនៅក្នុងអំឡុងរយៈពេល៣០ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ ដូចដែលតម្រូវដោយវិធាន ៨៩ ឡើយ [៣០] **គ.** ទោះបីជាសំណើរបស់ ក.ស.ព មិនត្រូវបានគេពិចារណាថាជាអញ្ញត្រកម្មក៏ដោយ សំណើរបស់ ក.ស.ព នៅតែមិនអាចទទួលយកបានដដែល ដោយសារអង្គជំនុំជម្រះសាលាដំបូង មិនអាចផ្លាស់ប្តូរច្បាប់ដែលយកមកអនុវត្ត ទៅតាមសំណើរបស់សហព្រះរាជអាជ្ញា [៣១] នោះទេ។

## II. ការឆ្លើយតបលើបញ្ហានីតិវិធី: សំណើធ្វើឡើងមិនទាន់ពេលវេលាដូច្នេះត្រូវតែបដិសេធ

១៤. អង្គជំនុំជម្រះសាលាដំបូង កំពុងត្រូវបានស្នើសុំឲ្យច្រានចោល សេចក្តីសម្រេចលើបញ្ហាយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវ ដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវតែមានចំណងទាក់ទងជាមួយជម្លោះប្រដាប់អាវុធ[៣២]។ នេះគឺជាអញ្ញត្រកម្ម ពាក់ព័ន្ធនឹងយុត្តាធិការរបស់ អ.វ.ត.ក។ អង្គជំនុំជម្រះសាលាដំបូង មិនអាចពិចារណាសំណើ អនុលោមតាមវិធាន៨៩ របស់ ក.ស.ព ដោយមិនបានកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាបឋមនោះទេ ព្រោះធាតុផ្សំទាំងនេះ មានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលឆ្នាំ១៩៧៥-១៩៧៩។

១៥. បញ្ហាថាតើ ស្ថិតក្នុងអំឡុងរយៈពេលយុត្តាធិការបណ្តោះអាសន្នរបស់ អ.វ.ត.ក ច្បាប់ទំនៀម

---

[២៨] សំណើរបស់ អៀង សារី សុំឲ្យមានសេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថា តើសហព្រះរាជអាជ្ញាអាចស្នើសុំឲ្យផ្លាស់ប្តូរការកំណត់បទចោទ នៅដំណាក់កាលនេះនៃនីតិវិធីដែរ ឬអត់ និងសំណើសុំពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនេះ បើសិនជាចម្លើយតបជាការចាំបាច់, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E103។

[២៩] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៤-១៦។

[៣០] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៧។

[៣១] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៨-២១, កថាខណ្ឌ ២៣។

[៣២] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០០-១៣។

ទម្លាប់អន្តរជាតិតម្រូវឲ្យមានចំណងទាក់ទងរវាងអំពើជាមូលដ្ឋាន នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធនោះ គឺជាបណ្តឹងជំទាស់យុត្តាធិការដែរ ឬយ៉ាងណា។ បញ្ហានេះត្រូវបាន លើកឡើងជាបញ្ហាជំទាស់យុត្តាធិការ តាមវិធាន ៧៤(៣)(ក) នៅដំណាក់កាលមុនសវនាការ ហើយអង្គបុរេជំនុំជម្រះយល់ឃើញថាអាចទទួលយកការប្តឹងជំទាស់យុត្តាធិការបាន។ សាលដីកាចែងថា៖ "ប្តឹងឧទ្ធរណ៍ថា៖ ... បង្ហាញថា "ការអនុវត្តទម្រង់នៃការទទួលខុសត្រូវនឹង រំលោភលើគោលការណ៍នីត្យានុកូលភាព" លើកឡើងនូវបណ្តឹងជំទាស់យុត្តាធិការជាកម្មវត្ថុអាច ទទួលយកបាន ដែលអាចធ្វើឡើងនៅក្នុង ដំណាក់កាលបុរេជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី"[៣៣]។

១៦. បណ្តឹងជំទាស់យុត្តាធិការនៅដំណាក់កាលសវនាការ ត្រូវបានចែងនៅក្នុងវិធាន ដែលត្រូវបាន អនុម័តយ៉ាងជាក់លាក់សម្រាប់ អ.វ.ត.ក[៣៤] និងមានអាទិភាពលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[៣៥]។ វិធាន ៨៩(១) ចែងថា អញ្ញត្រកម្មទាក់ទងទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង "ត្រូវ លើកឡើងយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ"។ ដោយសារដីកាដំណោះស្រាយ ចូលជាស្ថាពរ នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ នោះកាលបរិច្ឆេទផុតកំណត់សម្រាប់ការដាក់អញ្ញត្រកម្មនានា ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវ ដែលឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ត្រូវតែមានចំណងទាក់ទងជាមួយជម្លោះប្រដាប់អាវុធ គឺថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១[៣៦]។

---

[៣៣] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៥។

[៣៤] វិធាន ត្រូវបានកែប្រែដើម្បីបន្ថយរយៈពេលសម្រាប់ការលើកអញ្ញត្រកម្ម - នៅពេលនេះ បញ្ហាទាំងនេះ ត្រូវតែដោះស្រាយ ឲ្យបានល្អប្រសើរនៅមុនពេលសវនាការ។ ការធ្វើដូច្នេះ អវតក គឺមានលក្ខណៈស្រដៀងទៅនឹងតុលាការ *មិនអចិន្ត្រៃយ៍* ផ្សេងៗទៀត ដែលសុទ្ធតែតម្រូវឲ្យមានបញ្ហាយុត្តាធិការ - ដូចជា យុត្តាធិការរបស់តុលាការទៅលើឧក្រិដ្ឋកម្ម និងទម្រង់ នៃការ ទទួលខុសត្រូវជាក់លាក់ - ដែលនឹងត្រូវលើកឡើងនៅក្នុងរយៈពេលកំណត់ជាក់លាក់មួយ នៅមុនពេលចាប់ផ្តើម សវនាការ។ *សូមមើល* វិធាន ស្តីពីនីតិវិធី និងភស្តុតាង របស់ តុលាការ ICTY វិធាន ៧២(ក); វិធាន ស្តីពីនីតិវិធី និងភស្តុតាងរបស់ តុលាការ ICTR វិធាន ៧២(ក)។

[៣៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ឯកសារលេខ D55/I/8 កថាខណ្ឌ ១៤។

[៣៦] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9។

១៧. ក.ស.ព មិនបានដាក់អញ្ញត្រកម្មណាមួយ ដោយអនុលោមតាមវិធាន៨៩នោះទេ។ ប៉ុន្តែ *នៅពេលនេះ* ក.ស.ព ជំទាស់ទៅនឹងការកំណត់ព្រំដែនយុត្តាធិការ ដែលមានរយៈពេលប្រមាណចំនួន បួនខែ ក្រោយពីកាលបរិច្ឆេទផុតកំណត់សម្រាប់ការដាក់អញ្ញត្រកម្ម អនុលោមតាមវិធាន៨៩។ ជាមួយនឹងជម្រើស -អាចជាយុទ្ធវិធី ឬបណ្តាលមកការធ្វេសប្រហែសមិនយកចិត្តទុកដាក់របស់ខ្លួន- មិនដាក់អញ្ញត្រកម្ម *នៅពេលនេះ* ក.ស.ព ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង "កែតម្រូវ" លើនិយមន័យច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមរយៈការដកចេញនូវលក្ខខណ្ឌតម្រូវស្តីពី ទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ[៣៧]។ ក.ស.ព រៀបចំសំណើនេះ ដោយចាត់ទុកជាសំណើមួយ ធ្វើឡើងអនុលោមតាមវិធាន៩៨ ទៅវិញ[៣៨]។ វិធាន៩៨ មិនមែនជាមធ្យោបាយសម្រាប់ឲ្យគេចវេសពីវិធាន៨៩ នោះទេ។

១៨. បញ្ហានេះ ត្រូវបានលើកឡើងយ៉ាងទាន់ពេលវេលា និងប្តឹងផ្តល់យ៉ាងទូលំទូលាយនៅដំណាក់កាលបុរេជំនុំជម្រះរួចហើយ[៣៩]។ អង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៧៤(៣)(ក) បានសម្រេច តាមផ្លូវច្បាប់ជាផ្លូវការ ចំពោះបណ្តឹងជំទាស់យុត្តាធិការរួចហើយ[៤០]។ ក.ស.ព មិនបានធ្វើការជំទាស់។ ដូច្នេះសំណើនេះ ត្រូវតែបដិសេធចោល។

## III. ការឆ្លើយតបលើអង្គសេចក្តី: ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ

### ក. អង្គជំនុំជម្រះសាលាដំបូងមិនជាប់កាតព្វកិច្ចទៅនឹងការសម្រេចរបស់ខ្លួននានាក្នុងសំណុំរឿង០០១

១៩. អង្គបុរេជំនុំជម្រះ ពិចារណាឃើញថា "វាជាមូលដ្ឋានសម្រាប់តុលាការ ចំពោះកិច្ចដំណើរការនីតិវិធីមួយចំនួនដែលកំពុងរង់ចាំដំណោះស្រាយ ដែលថា សេចក្តីសម្រេចលើអង្គច្បាប់នៅក្នុងរឿងក្តីមួយ នឹងជាសេចក្តីណែនាំដល់តុលាការចំពោះរឿងក្តីស្រដៀងគ្នាលើកក្រោយ <u>នៅពេលដែលមិន</u>

---

[៣៧] សំណើ, កថាខណ្ឌ ១។

[៣៨] *ដូចដើងទំព័រខាងលើ*

[៣៩] *សូមមើល* សេចក្តីផ្តើម។

[៤០] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០០-១៣។ ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសំណើសុំឲ្យមានសវនាការផ្ទាល់មាត់

មានអំណះអំណាង ឬកាលៈទេសៈថ្មីត្រូវបានលើកឡើង[៤១]"។ ក.ស.ព មិនបានយកចិត្តទុកដាក់ចំពោះគោលការណ៍ណែនាំនេះទេ តាមរយៈការអះអាងថា អង្គជំនុំជម្រះសាលាដំបូង ត្រូវមាន "ការទទួលខុសត្រូវជាទូទៅមួយ ក្នុងការបង្កើតអង្គយុត្តិសាស្ត្រស៊ីសង្វាក់គ្នាមួយ ដែលអនុញ្ញាតឱ្យមានភាពប្រាកដប្រជាផ្នែកច្បាប់" [៤២] និងតាមរយៈ "ការប្រកាន់គោលជំហរស៊ីសង្វាក់គ្នាលើនិយមន័យជាធរមាន អំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងនៅក្នុងសំណុំរឿងលេខ០០១ និង០០២ អង្គជំនុំជម្រះសាលាដំបូងនឹងជួយលើកកម្ពស់ស្ថិរភាពច្បាប់ លើកទឹកចិត្តចំពោះសមត្ថភាពតុលាការ និងធ្វើឱ្យមានសង្គតិភាពនៃទម្លាប់នៃការអនុវត្តនៅ អ.វ.ត.ក ជាមួយនឹងទម្លាប់នៃការអនុវត្តរបស់តុលាការអន្តរជាតិដទៃទៀត..."[៤៣] ។ ក្រុមមេធាវីការពារក្តី យោងអំណះអំណាងផ្លូវច្បាប់របស់ខ្លួនពីពេលមុន ស្តីអំពីបញ្ហានេះដែលមានចែងនៅក្នុងចម្លើយតប នោះបានសេចក្តីថា *គោលការណ៍ប្រកាន់តាមសេចក្តីសម្រេចកន្លងមក (stare decisis)* មិនអាចយកមកអនុវត្តបានទេ ហើយក្រុមមេធាវីការពារក្តី បានលើកបញ្ហាថ្មី ដែលត្រូវអនុវត្ត *ដូចគ្នា* នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[៤៤]។

**ខ. គោលការណ៍នីត្យានុកូលភាព តម្រូវឱ្យអនុវត្តលក្ខខណ្ឌតម្រូវទំនាក់ទំនង នៅ អ.វ.ត.ក**

២០. ក.ស.ព បានអះអាងថា៖ "វាមានភាពប្រាកដថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងមាត្រា៥ រួមទាំងកង្វះខាតនៃលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនង គឺស្របគ្នានឹងគោលការណ៍នីត្យានុកូលភាព"[៤៥]។ និយមន័យជាក់លាក់របស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនស៊ីសង្វាក់ជាមួយគោលការណ៍នីត្យានុ

---

[៤១] *សំណុំរឿងក្តី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"*, ០០១/១៨-០៧-២០០៧-អវតក/កសចស(អបជ០២), សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាង ស្តីពីការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច", ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារលេខ D99/3/19 កថាខណ្ឌ ១៤។

[៤២] សំណើ, កថាខណ្ឌ ១២។

[៤៣] *ដូចជើងទំព័រខាងលើ*

[៤៤] ចម្លើយតប, កថាខណ្ឌ ៩១។

[៤៥] សំណើ, កថាខណ្ឌ ១៦។

កូលភាពនោះទេ គឺដោយសារតែនិយមន័យនោះ ខុសពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្ថិតក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩[៤៦]។ លើសពីនេះទៀត និយម

[៤៦] *សូមមើល* សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណ:ក្រៅផ្លូវការនានាពេលអនាគត ដែលត្រូវបានចេញជំនួសឱ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការដែលជាកម្មវត្ថុបណ្តឹងឧទ្ធរណ៍, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E51/4 កថាខណ្ឌ ២៧ *រួមទាំង* ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងបទល្មើសនៃការបាត់ខ្លួនមនុស្សដោយបង្ខំ និងសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ D180/4; សេចក្តីឆ្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យមានកិច្ចស៊ើបសួរ ស្តីអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ D188/3; ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អវតក, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ D378/2; ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងផ្តល់ជូននូវការអង្កេតបន្ថែម, ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D390/1/2/1.3 កថាខណ្ឌ ២៩-៦៥; បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ឯកសារលេខ D427/1/6 កថាខណ្ឌ ១៨៥-២៣២។ *សូមមើលផងដែរ* ចម្លើយតប នៅកថាខណ្ឌ ២-៤ កថាខណ្ឌ ៦-៧ កថាខណ្ឌ ១០ និងកថាខណ្ឌ ៨៦-១០៥។ សូមកត់សម្គាល់ផងដែរថា នៅចុងឆ្នាំ១៩៩៥ *គោលការណ៍សច្ចធារណ៍ធម្មានុរូប (opinion juris)* មិនបានឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់ត្រង់ចំណុចដែលមានភាពច្បាស់លាស់ថា រដ្ឋបានចាត់ទុកថា ទំនាក់ទំនងដែលជាលក្ខខណ្ឌតម្រូវនោះ លែងស្ថិតជាអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ *សូមមើល* របាយការណ៍របស់គណៈកម្មាធិការពិសេស ស្តីពីការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ, ឯកសារអង្គការសហប្រជាជាតិ លេខ Doc. A/50/22, អង្គការសហប្រជាជាតិ (ទីក្រុង ញូវយ៉ក ឆ្នាំ១៩៩៥) ("របាយការណ៍របស់គណៈកម្មាធិការពិសេស") កថាខណ្ឌ ៧៩: "មានទស្សនៈលើកឡើងខុសៗគ្នា ចំពោះបញ្ហា ថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចនឹងត្រូវប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលមានសន្តិភាព ដែរឬយ៉ាងណា ដោយពិចារណាដល់យុត្តិសាស្ត្រ Nüremberg ក៏ដូចជា លក្ខន្តិកៈរបស់តុលាការ *មិនអចិន្ត្រៃយ៍*នៅអតីតយូហ្គោស្លាវី។ គណៈប្រតិភូមួយចំនួនបានជ្រើសរើសចេញពីក្នុងចំណោមការវិវឌ្ឍន៍នានា ចាប់តាំងពីពេលមានយុត្តិសាស្ត្រ Nüremberg ដែលជំរុញឱ្យមានការគាំទ្រដល់ការមិនរាប់បញ្ចូលលក្ខខណ្ឌតម្រូវនានារបស់ជម្លោះប្រដាប់អាវុធ ដូចជា យុត្តិសាស្ត្រនៃ លក្ខន្តិកៈរបស់តុលាការ *មិនអចិន្ត្រៃយ៍*នៅរវ៉ាន់ដា និងសេចក្តីសម្រេចពេលថ្មីៗនេះ របស់តុលាការ *មិនអចិន្ត្រៃយ៍*សម្រាប់អតីតយូហ្គោស្លាវី នៅក្នុងរឿងក្តី Tadić។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ទស្សនៈនោះក៏នៅបានបង្ហាញឱ្យបានឃើញដែរថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងការចោទសួរនេះ តាមធម្មតាត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ និងលើកលែងតែចំពោះករណីស្ថិតក្នុងអំឡុងពេលមានសន្តិភាពតែប៉ុណ្ណោះ ដែលអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់ចំពោះបញ្ហានេះអាចនឹងត្រូវចោទជាសំណួរ ដោយសារភាពមិនចុះសម្រុងគ្នារបស់និយមន័យ ដែលមានចែងនៅក្នុងលិខិតុបករណ៍ផ្សេងៗ

ន័យ ដែលមានចែងនៅក្នុងមាត្រា៥ មិនអាចឲ្យគេព្យាករណ៍បាន និងមិនអាចឲ្យគេយកមកប្រើប្រាស់បាន ចំពោះករណីរបស់ លោក អៀង សារី ក្នុងអំឡុងពេលឆ្នាំពីឆ្នាំ១៩៧៥-១៩៧៩ នោះទេ។

**១. លក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងនឹងជម្លោះប្រដាប់អាវុធ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩**

**i. ធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុង Nuremberg (“ធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុង Nuremberg”)**

២១. អង្គបុរេជំនុំជម្រះបានរកឃើញថា អ្នកតាក់តែងសេចក្តីព្រាងធម្មនុញ្ញNuremberg បានធានាឲ្យមានទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ “ដើម្បីបញ្ចៀសការចោទប្រកាន់ថា ការវិនិច្ឆ័យទោសចេញឆ្ងាយពីអ្វីដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់អនុសញ្ញា”[៤៧]។ ក.ស.ព មិនយកចិត្តទុកដាក់លើការសម្រេចនេះ ហើយអះអាងថា “លក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងគ្នា ដែលមានចែងនៅក្នុងធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុង Nuremberg នោះ គឺវាគ្រាន់តែជាការកម្រិតមួយផ្នែកយុត្តាធិការតែប៉ុណ្ណោះ មិនមែនជាការដាក់កម្រិតដែលមានជាប់មកជាមួយស្រាប់ ទៅលើវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិនោះឡើយ”[៤៨]។ ក្រុមមេធាវីការពារក្តីសូមយោងលើសេចក្តីសន្និដ្ឋានផ្លូវច្បាប់មុនៗរបស់ខ្លួនលើបញ្ហានេះ ដូចបានលើកឡើងនៅក្នុងសារណាឆ្លើយតប[៤៩]។

---

គ្នា ហេតុដូច្នេះហើយ ទើបស្នើសុំឲ្យមានការពិចារណាបន្ថែមទៀត”។ *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tadić*, IT-94-1/AR72, សេចក្តីសម្រេច លើសារណារបស់មេធាវីការពារក្តី ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំលើយុត្តាធិការ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ ១៤១; រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blaškić*, IT-95-14, សាលក្រម, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ កថាខណ្ឌ ៧១។

[៤៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០៨។ *សូមមើលផងដែរនូវ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ D427/1/15 កថាខណ្ឌ ១៣៩។

[៤៨] សំណើ កថាខណ្ឌ ១៩។

[៤៩] សារណាឆ្លើយតប កថាខណ្ឌ ៨៧។

២២. ក.ស.ព អះអាងថា សេចក្តីយោងទៅលើពាក្យ "នៅមុនពេល ឬ ក្នុងពេលសង្គ្រាម" ដែលចែងក្នុង មាត្រា ៦(គ) នៃធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុង Nuremberg "បានឲ្យដឹងថា សញ្ញាណនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺមិនត្រូវបានកំណត់ ដូចដែលមានជាប់មកជាមួយស្រាប់ ដែល តម្រូវឲ្យមានតែក្នុងរង្វង់នៃពាក្យក្នុងអំឡុងពេលនៃសង្គ្រាមនោះឡើយ"[៥០]។ ការអះអាងដូច្នេះ គឺជា ការអះអាងដោយមិនត្រឹមត្រូវ ដោយហេតុថា ក.ស.ព ខ្លួនឯង បានយល់ច្រឡំលើលក្ខណៈអ្វីទៅ ដែលបង្កើតជា *ទំនាក់ទំនង* និងលើសាលក្រមរបស់តុលាការអន្តរជាតិនេះផងដែរ។ បញ្ហាចោទដែល ថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបាន "កំណត់ដូចដែលមានជាប់មកជាមួយស្រាប់ ដែល តម្រូវ ឲ្យមានតែក្នុងរង្វង់នៃពាក្យក្នុងអំឡុងពេលនៃសង្គ្រាមនោះដែរ ឬយ៉ាងណានោះ" គឺមាន លក្ខណៈខុសពីបញ្ហាចោទ ដែលថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមាន*ការជាប់ពាក់ព័ន្ធ*ជាសារវ័ន្ត នឹងឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព។ ក.ស.ព អះអាងថា សេចក្តីយោងនៅក្នុង សាលក្រមតុលាការអន្តរជាតិនេះ ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "នៅក្នុងនិយមន័យនៃ ធម្មនុញ្ញ" គឺគាំទ្រចំពោះ "សញ្ញាណ" ដែលថា លក្ខខណ្ឌដែលតម្រូវឲ្យមានទំនាក់ទំនង "គឺជា លក្ខខណ្ឌយុត្តាធិការ"[៥១]។ ការអះអាងនេះមិនមានមូលដ្ឋានគាំទ្រដោយឯកសារសំអាងណាមួយ ហើយជាការបកស្រាយដោយមិនត្រឹមត្រូវលើសេចក្តីដកស្រង់ ចេញពីសាលក្រមតុលាការអន្តរជាតិ ដែលត្រូវបានដកស្រង់ដោយ ក.ស.ព។ វាមិនមែនតាមរយៈពាក្យ "នៅក្នុងនិយមន័យនៃធម្មនុញ្ញ" នេះ ដែលជំរុញឲ្យយើងយល់ឃើញថា លក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនង អនុលោមតាមធម្មនុញ្ញ តុលាការអន្តរជាតិនាទីក្រុង Nuremberg គឺត្រឹមតែជាលក្ខខណ្ឌយុត្តាធិការនោះទេ។

**ii. ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ("ច្បាប់លេខ ១០") និងគោលការណ៍**Nuremberg

២៣. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា យុត្តិសាស្ត្រច្បាប់លេខ ១០ បានបញ្ជាក់សាជាថ្មីនូវទំនាក់ទំនង ជាមួយនឹងជម្លោះប្រដាប់អាវុធ[៥២]។ ក.ស.ព ដកស្រង់ច្បាប់លេខ ១០ នេះ មកធ្វើជាឧទាហរណ៍ ដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានអត្ថិភាពក្នុងនាមជា "ទស្សនាទានមួយដែលផ្សេងពី

---

[៥០] សំណើ កថាខណ្ឌ ១៩។

[៥១] *ដូចខាងលើ។*

[៥២] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០៨ ជើងទំព័រលេខ ៥៦៩។

ជម្លោះប្រដាប់អាវុធ ដែលស្ថិតនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ ១៩៧៥”។ ទោះបីជាលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងមិនត្រូវបានដាក់បញ្ចូលនៅក្នុងពាក្យពេចន៍ជាក់លាក់ នៅក្នុងច្បាប់លេខ ១០ ក៏ដោយ ក៏ការវិភាគរបស់ ក.ស.ព លើយុត្តិសាស្ត្រច្បាប់លេខ ១០ និងការធ្វើអត្ថាធិប្បាយជាប់ជាមួយ គឺជាការភ័ន្តច្រឡំ និងគ្មានអ្វីគួរឱ្យជឿជាក់ឡើយ។ ក.ស.ព បានយក *មតិយោបល់ដែលមិនទាក់ទងនឹងបញ្ហាចោទ* (*obiter dicta*) នៅក្នុងរឿងក្តីស្តីពី *បញ្ហាយុត្តិធម៌* និងរឿងក្តី*Einsatzgruppen* មកធ្វើជាសំអាងលើការអះអាងរបស់ខ្លួនថា “អវត្តមាននៃលក្ខខណ្ឌដែលតម្រូវឱ្យមានទំនាក់ទំនងដូចនៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ បានបើកឱ្យធ្វើការកាត់ទោសលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តមិនមែននៅក្នុងពេលសង្គ្រាម”។ ផ្ទុយមកវិញ ក.ស.ព បែរជាយក*សំអាងហេតុនៃសេចក្តីសម្រេចពីមុន* (*ratio decidendi*) នៅក្នុងរឿងក្តី*Flick* ទៅដាក់ក្នុងកំណត់សម្គាល់ជើងទំព័រទៅវិញ[៥៣]។ នៅក្នុងរឿងក្តីស្តីពី *បញ្ហាយុត្តិធម៌* បទចោទតែមួយគត់ (គឺបទចោទសមគំនិត) ត្រូវបានរកឃើញនៅក្នុងបទល្មើស ដែលបានប្រព្រឹត្តឡើងមុនពេលសង្គ្រាមលោកលើកទីពីរផ្ទុះឡើង ពោលគឺបទចោទនេះមិនមានការពាក់ព័ន្ធជាចម្បងទៅនឹងជម្លោះប្រដាប់អាវុធឡើយ[៥៤]។ សាលាក្តីនៅក្នុងរឿងក្តីនេះបានសម្រេចថា ខ្លួនពុំមានយុត្តាធិការជំនុំជម្រះលើបទសមគំនិត ថាជាបទល្មើសសំខាន់ និងដាច់ដោយឡែកមួយឡើយ[៥៥] ហើយសាលាក្តីនេះបានបើកចំហនូវបញ្ហាចោទឡើងមួយថាតើសាលាក្តីនេះនឹងពិចារណាលើភស្តុតាងនៃបទល្មើសដែលបានប្រព្រឹត្តឡើងមុនឆ្នាំ ១៩៣៩ ដែរឬទេ ប្រសិនបើបទល្មើសទាំងនេះត្រូវបានចោទប្រកាន់ពីបទចោទផ្សេងវិញមែននោះ[៥៦]។ សេចក្តីសង្កេតរបស់សាលាក្តីនេះ (ដែលបានដកស្រង់ដោយ ក.ស.ព) ដែលលើកឡើងថា លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងបាន “ដកចេញដោយចេតនាពីនិយមន័យនៃ” ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់លេខ ១០ ហេតុដូច្នេះ សេចក្តីសង្កេតនេះគឺជា *មតិយោបល់ដែលមិនទាក់ទងនឹងបញ្ហាចោទ*តែប៉ុណ្ណោះ។

---

[៥៣] សំណើ កថាខណ្ឌ ២០ ចំណុចយោងជើងទំព័រលេខ ៣០ និង ៣១។

[៥៤] របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះក្តីលើឧក្រិដ្ឋជនសង្គ្រាម ដែលត្រូវបានជ្រើសរើស និងរៀបចំដោយគណកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ វ៉ុលលីម IX ទីក្រុងឡុងដ៍ *អាចរកបាននៅលើគេហទំព័រ* http://www.loc.gov/rr/frd/Military_Law/pdf/Law-Reports_Vol-9.pdf ទំព័រទី ៤៦។

[៥៥] *ដូចខាងលើ*។

[៥៦] *ដូចខាងលើ*។

២៤. នៅក្នុងរឿងក្តី *Einsatzgruppen* ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានចោទប្រកាន់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងនៅចន្លោះខែ ឧសភា ឆ្នាំ ១៩៤១ និងខែ កក្កដា ឆ្នាំ ១៩៤៣ ពោលគឺក្នុងអំឡុងសម័យសង្គ្រាមលោកលើកទី II[៥៧]។ *មតិយោបល់*ដែលលើកឡើងដោយសាលាក្តីនេះថា ច្បាប់លេខ ១០ អនុញ្ញាតឲ្យមានការចោទប្រកាន់ឧក្រិដ្ឋកម្មទាំងឡាយ ដែលពុំបានប្រព្រឹត្តឡើងនៅក្នុងសម័យសង្គ្រាម ក៏ជា*មតិយោបល់ដែលមិនទាក់ទងនឹងបញ្ហាចោទ*ដែរ។ ម៉្យាងវិញទៀត នៅក្នុងរឿងក្តី *Flick* សាលាក្តីនេះបានសម្រេចថា គ្មាន "ការគាំទ្រណាមួយ" ចំពោះទទ្បីករណ៍ដែលបានលើកឡើងថា "ការមិនបញ្ចូល[ពាក្យពេចន៍ទំនាក់ទំនង]នៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ" ផ្តល់ជាភស្តុតាងនូវបំណងរបស់សាលាក្តីនេះ ចង់ពង្រីកវិសាលភាពនៃយុត្តាធិការរបស់ខ្លួន"។ ការសម្រេចដូច្នេះ ឃើញមានយ៉ាងជាក់លាក់តាមរយៈ *សំអាងហេតុនៃសេចក្តីសម្រេចពីមុន*។ នៅក្នុងរឿងក្តី *Flick* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានចោទប្រកាន់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមុនសម័យសង្គ្រាមលោកលើកទីពីរ ហើយសាលាក្តីនេះបានចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងឧក្រិដ្ឋភាពនៃប្រតិបត្តិការចំនួន ៤ ដែលបានបំពេញមុនពេលសង្គ្រាមផ្ទុះឡើង[៥៨]។ ហេតុដូច្នេះ រឿងក្តី *Flick* គួរតែត្រូវបានចាត់ទុកថាជាឯកសារដែលមានអានុភាពជាងនៅពេលពិចារណាថាតើយុត្តិសាស្ត្រច្បាប់លេខ ១០ គាំទ្រ ឬ មិនគាំទ្រលើការអះអាងថា លក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនង ត្រូវបានដកចេញពីច្បាប់នេះ។

២៥. ក.ស.ព បានកត់សម្គាល់ឃើញអំពីការពន្យល់រៀបរាប់ដោយពុំស៊ីសង្វាក់គ្នាយ៉ាងច្បាស់ក្រឡែតលើច្បាប់លេខ ១០ របស់អង្គបុរេជំនុំជម្រះ "ថាជាច្បាប់ក្នុងស្រុកសំខាន់បំផុត" នៅពេលដែលខ្លួនសម្រេចលើបញ្ហានេះ ព្រមទាំងលើការវាយតម្លៃរបស់ខ្លួន (នៅពេលពិចារណាថាតើសហឧក្រិដ្ឋកម្មរួមមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវដែរឬទេ យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩) ថា ច្បាប់លេខ ១០ បានឆ្លុះបញ្ចាំង "ឲ្យឃើញពីការព្រមព្រៀងគ្នាជាអន្តរជាតិ រវាងបណ្តាប្រទេសមហាអំណាចលើច្បាប់ជាធរមានសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិនានា"[៥៩]។ ទោះបីជាក្រុមមេធាវីការពារក្តីឯកភាពជាមួយនឹង ក.ស.ព ថា អង្គបុរេ

---

[៥៧] *ដូចខាងលើ* ទំព័រទី ៤៧។

[៥៨] *ដូចខាងលើ*។

[៥៩] សំណើ កថាខណ្ឌ ២១។

ជំនុំជម្រះពិតជាសម្រេចដោយពុំស៊ីសង្វាក់គ្នាលើឋានៈនៃច្បាប់លេខ ១០ ក៏ពិតមែន ក៏ក្រុមមេធាវីការពារក្តីនៅតែអះអាងថា តុលាការសម្ព័ន្ធមិត្ត និងតុលាការអាល្លឺម៉ង់ ដែលបានអនុវត្តច្បាប់លេខ ១០ នោះ ត្រូវបានចាត់ទុកថាជា "តុលាការក្នុងស្រុក ដែលយកច្បាប់ក្នុងស្រុក (ជាតិ) មកអនុវត្តជាចម្បង"[៦០] ហើយនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់[តុលាការយោធាអន្តរជាតិ] ត្រូវបានគេមើលឃើញថា ជាសេចក្តីប្រកាសនៃនីតិអន្តរជាតិ ដែលភាគច្រើនត្រូវបានគេទទួលស្គាល់ភ្លាមៗ ក្រោយពីមហាន្តរាយនៃសង្គ្រាមលោកលើកទីពីរ"[៦១]។ គោលការណ៍ Nuremberg (ដែលនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចគ្នានឹងនិយមន័យនៅក្នុងធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុង Nuremberg) ឆ្លុះបញ្ចាំងនូវការយល់ដូច្នេះ[៦២]។

### iii. អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍

២៦. អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ "ពិតជាបានងាកចេញយ៉ាងច្បាស់លាស់ពីនិយមន័យដើមរបស់វា ដែលមានចែងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយតម្រូវឲ្យមាន "ចេតនាជាក់លាក់" ជាធាតុផ្សំមួយ ដែលមិនមានចែងនៅក្នុងធម្មនុញ្ញតុលាការ Nuremberg"[៦៣]។ អង្គបុរេជំនុំជម្រះបានបន្ថែមទៀតថា "មកត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥

---

[៦០] Egon Schwelb *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ២៣ B.Y.B. ច្បាប់អន្តរជាតិ ១៧៨, ២១៨-២១៩ (ឆ្នាំ ១៩៤៦)។ *សូមមើលផងដែរនូវ* Attila Bogdan, *ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនៅក្នុងការអនុវត្ត "សហឧក្រិដ្ឋកម្មរួម" នៅក្នុងយុត្តិសាស្ត្រសាលាក្តីអន្តរជាតិមិនអចិន្ត្រៃយ៍សម្រាប់អតីតប្រទេសយូហ្គោស្លាវី* ៦ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ កែប្រែលើកទី ៦៣, ១១០ (ឆ្នាំ ២០០៦)។ ច្បាប់លេខ ១០ "មិនអាចចាត់ទុកជាផ្នែកមួយនៃច្បាប់អន្តរជាតិឡើយ ដោយហេតុថា ច្បាប់នេះបានអនុម័តដោយអង្គនីតិបញ្ញត្តិ សម្រាប់អនុវត្តលើអាល្លឺម៉ង់ (ក្រុមប្រឹក្សាគ្រប់គ្រងសម្ព័ន្ធមិត្ត)។ ហេតុដូច្នេះហើយ សេចក្តីសម្រេចដែលបានធ្វើឡើង អនុលោមតាមច្បាប់លេខ ១០ មិនបង្កើតជាយុត្តិសាស្ត្រអន្តរជាតិដ៏ត្រឹមត្រូវឡើយ..." (គូសបញ្ជាក់បន្ថែម)។

[៦១] *សូមមើល* Stuart Ford *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖ តើវាទាមទារឲ្យមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធដែរឬទេ?* ២៤ UCLA PAC. BASIN L.J. ១២៥, ១៤៨, ១៥១ (ឆ្នាំ ២០០៦ ដល់ ឆ្នាំ២០០៧)។

[៦២] គោលការណ៍Nuremberg គោលការណ៍ទី VI(គ)។

[៦៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០៩។

មានប្រទេសត្រឹមតែ ២៥ ប៉ុណ្ណោះ ដែលបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬ ចូលជាភាគីនៃអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ឆ្នាំ ១៩៧៣ ក្នុងចំណោមប្រទេសសរុប *១៣៤* ដែលជាសមាជិកអង្គការសហប្រជាជាតិ និងមានប្រទេសចំនួន ៣២ បន្ថែមទៀត ដែលបានចុះហត្ថលេខាក្នុងអំឡុងពេលយុត្តាធិការក្នុងពេលវេលារបស់ អ.វ.ត.ក ក្នុងចំណោមប្រទេសជាសមាជិកបានកើនឡើងរហូតដល់ចំនួន ១៤៨”[៦៤]។ ក.ស.ព មិនយកចិត្តទុកដាក់លើសេចក្តីសង្កេតទាំងនេះ ហើយបានអះអាងថា ករណីដែលអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ និងអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ឆ្នាំ ១៩៧៣ “កំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់ខ្លួនដោយមិនភ្ជាប់ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ បានបង្ហាញយ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមានទំនាក់ទំនងទាំងស្រុង ទៅនឹងជម្លោះប្រដាប់អាវុធនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ”[៦៥]។ ក្រុមមេធាវីការពារក្តីសូមយោងលើសេចក្តីសន្និដ្ឋានផ្លូវច្បាប់មុនៗរបស់ខ្លួនលើបញ្ហានេះ ដូចបានលើកឡើងនៅក្នុងសារណាឆ្លើយតប[៦៦]។

## iv. សេចក្តីព្រាងក្រម ស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ របស់គណៈកម្មការច្បាប់អន្តរជាតិ ឆ្នាំ ១៩៥៤ (“សេចក្តីព្រាងក្រមស្តីពីបទល្មើសឆ្នាំ ១៩៥៤”)

២៧. អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា សេចក្តីព្រាងក្រមស្តីពីបទល្មើសឆ្នាំ ១៩៥៤ “មិនត្រូវបានអនុម័តទទួលយកដោយមហាសន្និបាតអង្គការសហប្រជាជាតិទេ”[៦៧]។ ក.ស.ព មិនបានយកចិត្តទុកដាក់លើសេចក្តីសង្កេតនេះ ហើយបានអះអាងថា និយមន័យនៃ “ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍” និង “អំពើអមនុស្សធម៌នានា...ប្រឆាំងប្រជាជនស៊ីវិលណាមួយ” នៅក្នុងសេចក្តីព្រាងក្រមស្តីពីបទល្មើសឆ្នាំ ១៩៥៤ គឺជា “ភស្តុតាងដទៃៗទៀតអំពីទម្លាប់អនុវត្ត និង *សច្ចធារណ៍ធម្មានុរូបនៃអំពើ* (*opinion juris*) របស់រដ្ឋ នៅមុនឆ្នាំ ១៩៧៥ [ពោលគឺជាការគាំទ្រ]បន្ថែមទៀតដល់សញ្ញាណ

---

[៦៤] *ដូចខាងលើ*។

[៦៥] សំណើ កថាខណ្ឌ ២៣។

[៦៦] សារណាឆ្លើយតប កថាខណ្ឌ ៨៤។

[៦៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០៩។

ដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចត្រូវបានប្រព្រឹត្តនៅក្រៅជម្លោះប្រដាប់អាវុធ”[៦៨]។ ក្រុមមេធាវីការពារក្តី សូមយោងលើសេចក្តីសន្និដ្ឋានផ្លូវច្បាប់មុនៗរបស់ខ្លួនលើបញ្ហានេះ ដូចបានលើកឡើងនៅក្នុងសារណាឆ្លើយតប[៦៩]។

## v. អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីភាពមិនអាចអនុវត្តទៅបាននៃអាជ្ញាយុកាល លើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

២៨. អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា “មកត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មានប្រទេសចំនួនត្រឹមតែ ១៨ ប៉ុណ្ណោះ ក្នុងចំណោមប្រទេសសរុបចំនួន ១៣៤ ដែលបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬ ចូលជាភាគីនៃអនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីភាពមិនអាចអនុវត្តទៅបាននៃអាជ្ញាយុកាលលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយមានតែរដ្ឋមួយបន្ថែមទៀតប៉ុណ្ណោះដែលផ្តល់សច្ចាប័នដល់លក្ខន្តិកៈនេះក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក...។ គេមិនអាចនិយាយបានថា អនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ ១៩៦៨ ស្របទៅនឹងកម្រិតនៃការទទួលយកមួយដើម្បីក្លាយជាការអនុវត្តទូទៅបានទេ”[៧០]។ ក.ស.ព មិនបានយកចិត្តទុកដាក់លើសេចក្តីសង្កេតនេះ ហើយបានដកស្រង់ ករណីដែលមិនមានចែងអំពីលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនង នៅក្នុងអនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីភាពមិនអាចអនុវត្តទៅបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម មកធ្វើជាភស្តុតាងបន្ថែមបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចត្រូវបានប្រព្រឹត្តនៅក្រៅជម្លោះប្រដាប់អាវុធនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[៧១]។

---

[៦៨] សំណើ កថាខណ្ឌ ២៣។

[៦៩] សារណាឆ្លើយតប កថាខណ្ឌ ៨៨។ *សូមមើលផងដែរនូវ* របាយការណ៍របស់គណកម្មាធិការមិនអចិន្ត្រៃយ៍ កថាខណ្ឌ ៨០៖ “ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ទស្សនមួយបានលើកឡើងថា ភាពជាន់គ្នាណាមួយរវាងប្រភេទបទល្មើសទាំងពីរ ត្រូវជៀសវាង ហើយបទដ្ឋាននៃការបង្ហាញដូចគ្នា គួរជាលក្ខខណ្ឌទាមទារសម្រាប់ឧក្រិដ្ឋកម្មទាំងពីរ បើទោះលក្ខខណ្ឌចេតនា មានភាពខុសគ្នាក៏ដោយ”។

[៧០] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០៩។

[៧១] សំណើ កថាខណ្ឌ ២៣។

ក្រុមមេធាវីការពារក្តីសូមយោងសេចក្តីសន្និដ្ឋានផ្លូវច្បាប់មុនៗរបស់ខ្លួនលើបញ្ហានេះ ដូចបានលើកឡើងនៅក្នុងសារណាឆ្លើយតប[៧២]។

### vi. ច្បាប់ឆ្នាំ ១៩៥០ ស្តីពី (ការផ្តន្ទាទោស) របបណាស៊ីអ៊ីស្រាអែល និងសហការីទាំងឡាយនៃរបបណាស៊ី

២៩. អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា "មានឧទាហរណ៍មួយចំនួនតូចនៅក្នុងច្បាប់ជាតិ ដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំចាំបាច់មានលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនេះ។ [លើកលែងតែពីសម័យអាល្លឺម៉ង់រហូតដល់មានច្បាប់លេខ ១០ ចេញ] ឧទាហរណ៍មួយនៃការមិនរាប់បញ្ចូលនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនៅក្នុងច្បាប់ជាតិ មាននៅក្នុងច្បាប់ប្រទេសអ៊ីស្រាអែលឆ្នាំ ១៩៥០ ដែលបង្ហាញពីលក្ខណៈពិសេសតែមួយគត់របស់វា"[៧៣]។ ក.ស.ព មិនបានយកចិត្តទុកដាក់លើសេចក្តីសង្កេតនេះ ហើយបានដកស្រង់ច្បាប់ឆ្នាំ ១៩៥០ ស្តីពី (ការផ្តន្ទាទោស) របបណាស៊ីអ៊ីស្រាអែល និងសហការីទាំងឡាយនៃរបបណាស៊ី មកធ្វើជាភស្តុតាងបន្ថែមបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចត្រូវបានប្រព្រឹត្តនៅក្រៅជម្លោះប្រដាប់អាវុធនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[៧៤]។ ក្រុមមេធាវីការពារក្តីសូមយោងលើសេចក្តីសន្និដ្ឋានផ្លូវច្បាប់មុនៗរបស់ខ្លួនលើបញ្ហានេះ ដូចបានលើកឡើងនៅក្នុងញត្តិ[៧៥]។

## ២. លោក អៀង សារី ពុំអាចប្រមើលមើលឃើញ និងពុំអាចដឹងថាមានច្បាប់ចែងថា លោកអាចទទួលខុសត្រូវលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងនៅក្រៅជម្លោះប្រដាប់អាវុធ

៣០. សហព្រះរាជអាជ្ញាអះអាងថា "គេអាចព្យាករណ៍ទុកជាមុនបាន ដោយមិនមានការសង្ស័យអ្វីទេថា គេអាចដាក់ឲ្យជនជាប់ចោទទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា មិនថាមាន ឬ គ្មានអត្ថិភាពនៃជម្លោះប្រដាប់អាវុធមួយនៅពេលពាក់ព័ន្ធគ្នានោះ ឡើយ"[៧៦]។ ទោះបីជា ក.ស.ព បានកំណត់បទដ្ឋាននៃភាពអាចប្រមើលមើលឃើញ ដូច

---

[៧២] សារណាឆ្លើយតប កថាខណ្ឌ ៩០។

[៧៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០៩ (គូសបញ្ជាក់បន្ថែម)។

[៧៤] សំណើ កថាខណ្ឌ ២៣។

[៧៥] ញត្តិ ចំណុចលេខយោងជើងទំព័រលេខ ២៧។

[៧៦] សំណើ កថាខណ្ឌ ២៤។

បានបញ្ជាក់ច្បាស់នៅក្នុងយុត្តិសាស្ត្រ អ.វ.ត.ក ពោលគឺ "ជនជាប់ចោទត្រូវតែមានលទ្ធភាពវាយតម្លៃខ្ពស់បានអំពើនោះ គឺមានលក្ខណៈឧក្រិដ្ឋនៅក្នុងន័យ ដែលយល់បានជាទូទៅដោយពុំមានការយោងទៅដល់បញ្ញត្តិជាក់លាក់ណាមួយឡើយ"[៧៧] ក៏ដោយ ក៏ ក.ស.ព ខកខានពុំបានអនុវត្តបទដ្ឋាននេះឲ្យបានត្រឹមត្រូវ។ ក.ស.ព អះអាងថា "អំពីវិសាលភាពដែលថា វាពុំមានភាពច្បាស់លាស់អំពីថាតើលក្ខខណ្ឌតម្រូវស្តីពីអត្ថិភាពនៃទំនាក់ទំនងក្នុងចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ដំណោះស្រាយតាមសេចក្តីសម្រេចចុងក្រោយតាមផ្លូវតុលាការអំពីភាពមិនច្បាស់លាស់នោះ គឺអាចព្យាករណ៍ទុកជាមុនបានរួចជាស្រេច"[៧៨]។ ចំណុចទីមួយ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ កើតចេញពីការអនុវត្ត និង *សច្ចធារណ៍ធម្មានុរូបនៃអំពើ*របស់រដ្ឋ[៧៩]។ យ៉ាងច្រើនបំផុតនោះ សេចក្តីសម្រេចចុងក្រោយតាមផ្លូវតុលាការគឺជាយន្តការបន្ទាប់បន្សំ នៅក្នុងការកំណត់អំពីវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិតែប៉ុណ្ណោះ[៨០]។ ចំណុចទីពីរ ដូចដែល ក.ស.ព បានស្នើឡើង ដើម្បីវាយតម្លៃថាតើការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាមទារ ឬ ពុំទាមទារឲ្យភ្ជាប់ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនោះ វាពុំតម្រូវឲ្យយើងធ្វើការវាយតម្លៃថាតើគេអាចប្រមើលមើលឃើញដែរឬទេថាវិធានទំនៀមទម្លាប់អាចមានលក្ខណៈកាន់តែជាក់លាក់ និងរឹងមាំនាពេលអនាគត។ និយាយក្នុងន័យម្យ៉ាងទៀតនោះគឺ បើទោះជាមានភាពពុំច្បាស់លាស់ពាក់ព័ន្ធនឹងការដកចេញនូវលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ក៏ដោយ ភាពពុំច្បាស់លាស់នោះនឹងពុំអាចឲ្យយើងមានលទ្ធភាព "អាចយល់ជាទូទៅ" ថា ការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ដែលពុំមានលក្ខខណ្ឌតម្រូវឲ្យទំនាក់ទំនង) អាចឲ្យគេប្រមើលមើលឃើញបាន។

៣១. ចំពោះលក្ខខណ្ឌតម្រូវនៃការដឹងថាមានច្បាប់ចែងវិញ ក្រុមមេធាវីការពារក្តីកត់សម្គាល់ឃើញការសម្រេចរបស់អង្គបុរេជំនុំជម្រះថា "វាក៏រួមបញ្ចូលសំអាងច្បាប់ទាំងឡាយណាដែលផ្អែកលើទំនៀម

---

[៧៧] *ដូចខាងលើ*។

[៧៨] *ដូចខាងលើ* កថាខណ្ឌ ២៥។

[៧៩] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០ D97/14/5 ឧបសម្ព័ន្ធ ក ផ្នែក II (ច) ចំពោះការពិភាក្សាលម្អិតលើការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

[៨០] *សូមមើល* លក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ (ត.យ.អ) មាត្រា ៣៨(១)(៣) ដែលចែងថា ត.យ.អ អាចចាត់ទុកយុត្តិសាស្ត្រមុនៗរបស់ខ្លួន "ជាយន្តការបន្ទាប់បន្សំនៅក្នុងកំណត់លើវិធានគតិយុត្តិ"។

ទម្លាប់ផងដែរ"[៨១]។ ហេតុដូច្នេះ ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថាតើលោក អៀង សារី អាចដឹងដែរឬទេថា នៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ មាននិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមិនទាមទារនូវលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនង គឺជាសេចក្តីសម្រេចដែលត្រូវគោរពទៅតាម និងអាស្រ័យទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថាតើលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនង ពិតជាមានអត្ថិភាពនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងសម័យនោះដែរឬទេ។ ក្រុមមេធាវីការពារក្តីសូមសូមយោងលើសេចក្តីសន្និដ្ឋានផ្លូវច្បាប់មុនៗរបស់ខ្លួនលើលក្ខខណ្ឌនៃភាពអាចប្រមើលមើលឃើញថាមានបទល្មើស និងលក្ខខណ្ឌនៃការដឹងថាមានច្បាប់ចែង ដូចបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី លើដីកាដំណោះស្រាយ[៨២]។

**ខ. គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio pro reo*) អាចយកមកធ្វើជាមូលដ្ឋានដ៏សមរម្យមួយ នៅក្នុងការដោះស្រាយជម្លោះពាក់ព័ន្ធនឹងឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ**

៣២. ក.ស.ព បានអះអាងថា គោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* "មិនអាចប្រើប្រាស់ធ្វើជាមូលដ្ឋានមួយនៅក្នុងការដោះស្រាយជម្លោះនានា ស្តីពីបញ្ហាច្បាប់សុទ្ធសាធនោះឡើយ ជាពិសេស ជម្លោះនានាស្តីពីការបកស្រាយច្បាប់ទំនៀមទម្លាប់អន្តរជាតិឱ្យបានត្រឹមត្រូវ"[៨៣]។ ម៉្យាងវិញទៀត ក.ស.ព បានអះអាងថា "ការអនុវត្តបែបណាមួយក៏ដោយស្តីពីការសម្រេចលើបញ្ហាពិបាកៗ ឬ "មិនច្បាស់លាស់" ទាក់ទងទៅនឹងច្បាប់តាមទម្លាប់អន្តរជាតិ ដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទ គួរតែត្រូវបានកម្រិតឱ្យត្រឹមតែកាលៈទេសៈលើកលែង បានហើយកាលណាមិនមានវិធានផ្សេងៗឯណា ដែលស្តីពីការបកស្រាយ អាចជួយរកដំណោះស្រាយលើបញ្ហានោះបាន និងកាលណាបញ្ហាស្តីពីភាពត្រឹមត្រូវយ៉ាងខ្លាំងនោះ មានភាពធ្ងន់ធ្ងរជាងការចាំបាច់ក្នុងការជំទាស់ ដើម្បីរក្សានូវប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិមួយ ដែលអាចដំណើរការបាន"[៨៤]។

---

[៨១] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ D97/14/15 កថាខណ្ឌ ៥៥។

[៨២] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣០ ដល់ កថាខណ្ឌ ១៣៥។

[៨៣] សំណើ កថាខណ្ឌ ២៧ (គូសបញ្ជាក់បន្ថែម)។

[៨៤] *ដូចខាងលើ* កថាខណ្ឌ ៣២ (គូសបញ្ជាក់បន្ថែម)។

សេចក្តីអះអាងទាំងនេះមិនត្រឹមតែពុំស៊ីសង្វាក់គ្នាប៉ុណ្ណោះទេ វាក៏ពុំមានការគាំទ្រពីយុត្តិសាស្ត្រអន្តរជាតិ និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ដែល ក.ស.ព បានយកមកធ្វើជាមូលដ្ឋាន នោះផងដែរ។

៣៣. ចំណុចទីមួយ ការសម្រេចនៅក្នុងរឿងក្តី *Stakić* ដោយអង្គជំនុំជម្រះសាលាដំបូងថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* "អនុវត្តបានតែលើការសម្រេចលើអង្គហេតុតែប៉ុណ្ណោះ ពុំមែនអង្គច្បាប់ទេនោះ"[៨៥] ការសម្រេចបែបនេះ មិនមានការគាំទ្រពីឯកសារសំអាងណាមួយឡើយ ហើយបានទទួលរងនូវរិះគន់តាមផ្លូវតុលាការទៀតផង[៨៦]។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *Galić* បានលើកឡើងថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*នេះ "គ្របដណ្តប់ទាំង" វិមតិសង្ស័យ ពាក់ព័ន្ធ "ថាតើបទល្មើសមួយត្រូវបានបង្ហាញពិតជាកើតឡើងដែរឬយ៉ាងណា"[៨៧]។ ករណីនេះបើកឱ្យមានលទ្ធភាពមួយថា *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ក៏អាចគ្របដណ្តប់លើករណីថាតើគោលការណ៍ច្បាប់ជាក់លាក់មួយ កំពុងមានអត្ថិភាព (ឬធ្លាប់មានអត្ថិភាព) នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែរឬក៏

---

[៨៥] *រដ្ឋអាជ្ញា ទល់នឹង* Stakić សាលក្រម IT-97-24-T ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៤១៦ *ដកស្រង់នៅក្នុង* សំណើសុំ ក្នុងជើងទំព័រលេខ ៥១។

[៨៦] *សូមមើល រដ្ឋអាជ្ញា ទល់នឹង Limaj* សេចក្តីប្រកាសរបស់ចៅក្រម Shahabuddeen IT-03-66-A ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៖ "នៅក្នុងរឿងក្តី *Stakić* អង្គជំនុំជម្រះសាលាដំបូង ដោយយោងលើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* បានលើកឡើងថា "គោលការណ៍នេះអនុវត្តតែចំពោះការសម្រេចលើអង្គហេតុ មិនមែនអង្គច្បាប់ឡើយ។ កាលៈទេសៈដែលថា គ្មានឯកសារសំអាងណាមួយបានផ្តល់ជូននោះ ទំនងជាអាចបង្ហាញថា សេចក្តីប្រកាសនេះមិនតម្រូវឱ្យមានឯកសារសំអាងទាំងនេះឡើយ ដោយហេតុថា តាមការសន្មត គោលការណ៍នេះបានបង្កើតឡើងយ៉ាងជាក់លាក់នៅក្នុងការអនុវត្តច្បាប់"។ ទោះបីជាយ៉ាងនេះក្តី តាមដែលខ្ញុំយល់ ឯកសារទាំងនេះជំរុញឱ្យមានភាពសង្ស័យថាតើគោលការណ៍នេះកម្រិតលើតែអង្គហេតុ ឬក៏យ៉ាងណា។ ប្រហែលជាភាគច្រើនទៅ គោលការណ៍នេះអាចយកមកអនុវត្តលើអង្គហេតុ ក៏ប៉ុន្តែ ខ្ញុំមិនជឿថា គោលការណ៍នេះមិនអាចអនុវត្តលើអង្គច្បាប់ឡើយ។ មិនថាវិធានសម្រាប់ការបកស្រាយបទប្បញ្ញត្តិនៃអនុសញ្ញា មានលក្ខណៈច្បាស់លាស់ត្រឹមកម្រិតណានោះទេ យើងត្រូវចងចាំគោលការណ៍នេះនៅ ក្នុងពេលអនុវត្តវិធានទាំងនោះ។ មិនតែប៉ុណ្ណោះ ក្រៅពីបទប្បញ្ញត្តិទាំងនោះ យើងអាចឃើញមានកើតឡើងបញ្ហាអង្គច្បាប់"។

[៨៧] *រដ្ឋអាជ្ញា ទល់នឹង* Galiić សាលដីកា IT-98-29-A ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ៧៧ *ដកស្រង់នៅក្នុង* សំណើសុំក្នុងចំណុចយោងជើងទំព័រលេខ ៥២។

យ៉ាងណា[៨៨]។ យុត្តិសាស្ត្ររបស់សាលាក្តី *មិនអចិន្ត្រៃយ៍* នានា ដែលបានដកស្រង់ដោយ ក.ស.ព ពុំមានលក្ខណៈរឹងមាំ។ ចំណុចទីពីរ អង្គជំនុំជម្រះតុលាការកំពូលរបស់ អ.វ.ត.ក បានសម្រេចរួច ហើយថា អនុលោមតាមវិធានស្តីពីការបកស្រាយនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តបានចំពោះវិមតិសង្ស័យពាក់ព័ន្ធនឹងខ្លឹមសារច្បាប់[៨៩]។

៣៤. ការអនុវត្ត គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនមានភាពចាំបាច់នៅក្នុងរឿងក្តីនេះឡើយ។ សេចក្តីសន្និដ្ឋានទាំងឡាយដែលបានលើកឡើងនៅក្នុងនេះ រួមជាមួយនឹងសេចក្តីសន្និដ្ឋានមុនៗពីក្រុមមេធាវីការពារក្តី បានបង្ហាញថា លក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនង នៅតែមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។ ក៏ប៉ុន្តែ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងនៅតែមានបំណងចង់សម្រេចលើបញ្ហានេះទៀតនោះ ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងគួរអនុវត្តតាមអង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះតុលាការកំពូល ហើយគួរសម្រេចថា នៅក្នុងកាលៈទេសៈពិសេសៗមួយចំនួន

---

[៨៨] ការវិភាគដូចគ្នា អាចយកមកអនុវត្ត *ដោយគ្មានការកែប្រែ* ចំពោះសេចក្តីដកស្រង់នានា ចេញមកពីសាលដីកាលើរឿងក្តី *Renzahu* និង *Halilović* ដែលត្រូវបានដកស្រង់យកមកដាក់នៅក្នុងសំណើ កថាខណ្ឌ ២៨។ *សូមមើល រដ្ឋអាជ្ញា ទល់នឹង Renzahu* សាលដីកា ICTR-97-31-A ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៧២ ដល់ កថាខណ្ឌ ៤៧៥។ *រដ្ឋអាជ្ញា ទល់នឹង Halilović* សាលដីកា IT-01-48-A ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៧ កថាខណ្ឌ ១០៩។

[៨៩] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ E50/3/1/4 កថាខណ្ឌ ៣១៖ "អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់យ៉ាងមុតមាំថា គោលការណ៍នេះដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលកើតចេញពីគោលការណ៍ការសន្មតទុកជាមុនថាគ្មានទោស និងដែលមានចែងជាមូលដ្ឋានក្នុងប្រព័ន្ធគតិយុត្តិរបស់កម្ពុជាផងដែរនោះ មានមុខងារជាចម្បងក្នុងការបង្ហាញឲ្យឃើញនូវការយល់ដឹងជាស្វ័យប្រវត្តិ ក្នុងករណីដែលពុំមានភស្តុតាងលុបបំបាត់ភាពមន្ទិលសង្ស័យ។ ចំពោះគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តបានចំពោះស្ថានភាពលំបាកនៃអត្ថន័យច្បាប់ គោលការណ៍នេះត្រូវកម្រិតត្រឹមតែភាពមន្ទិលសង្ស័យដែលនៅតែមានក្រោយការបកស្រាយ។ ហេតុដូច្នេះ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវតែអនុវត្តយ៉ាងត្រឹមត្រូវចំពោះភាពមន្ទិលសង្ស័យអំពីខ្លឹមសារនៃបទដ្ឋានគតិយុត្តិ ដែលនៅតែមានក្រោយការអនុវត្តនូវវិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល...ដូចនេះ តាមការអនុវត្តជាក់ស្តែង គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នឹងមិនមានភាពចាំបាច់ក្នុងការដោះស្រាយទៅលើ *ភាពខ្វះចន្លោះ* នៃច្បាប់ឡើយ ប៉ុន្តែ អាចនឹងដើរតួនាទីក្នុងករណីដែលមានវិវាទបទដ្ឋានច្បាប់នានា"។

គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តបានចំពោះអង្គច្បាប់នៅចំពោះមុខ អ.វ.ត.ក។

## IV. **សេចក្តីសន្និដ្ឋាន និងសំណើសុំ**

៣៥. បញ្ហាទាំងឡាយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺពាក់ព័ន្ធនឹងអញ្ញត្រកម្មនៅក្នុងវិធាន ៨៩(១) ពោលគឺ បញ្ហានៃការអនុវត្តច្បាប់។ អង្គបុរេជំនុំជម្រះបានដោះស្រាយបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងករណីថាតើធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមបញ្ចូលទំនាក់ទំនងរវាងអំពើប្រព្រឹត្ត និងជម្លោះប្រដាប់អាវុធដែរឬទេ។ អង្គបុរេជំនុំជម្រះបានសម្រេចថា លក្ខខណ្ឌនេះជាលក្ខខណ្ឌតម្រូវមួយ។ ក.ស.ព មិនបានយកចិត្តទុកដាក់ពិនិត្យមើលវិធាន ៨៩(១) ហើយពុំបានដាក់អញ្ញត្រកម្មទាំងនេះឡើយ។ នៅក្នុងពេលនេះ ក.ស.ព ពុំអាចធ្វើសំណើក្នុងទម្រង់ជាការស្នើសុំឲ្យកែប្រែបទចោទចំពោះអង្គហេតុដែលមាន ក្នុងគោលបំណងធ្វើជាមធ្យោបាយដើម្បីគេចពីការអនុវត្តវិធាន ឬ កែតម្រូវនូវភាពពុំបានយកចិត្តទុកដាក់របស់ខ្លួនឡើយ។ បើទោះជាអង្គជំនុំជម្រះសាលាដំបូងសម្រេចពិចារណាលើសំណើនេះ អនុលោមតាមវិធាន ៨៩ ក៏ដោយ សំណើនេះគួរត្រូវច្រានចោលលើអង្គសេចក្តី។

**អាស្រ័យហេតុនេះ** ដោយយោងទៅតាមហេតុផលដូចបានរៀបរាប់ជូនខាងលើ អង្គជំនុំជម្រះសាលាដំបូងគួរ៖

ក. **បដិសេធ**ចោលសំណើនេះ ដោយហេតុពុំបានដាក់ក្នុងរយៈពេលកំណត់ ឬ បើមិនដូច្នោះទេ

ខ. **សម្រេច**បើកសវនាការដេញដោលដោយផ្ទាល់មាត់ និងជាសាធារណៈ ព្រមទាំង

គ. **ច្រានចោល**សំណើនេះលើអង្គសេចក្តី។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកបណ្តឹងនេះដោយក្តីគោរព

_______________ _______________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា **ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១**